










# ហ្វារពន្លឺសិល្បៈ ឈ្នះពានរង្វាន់ Shorty Impact Awards ដំបូងបំផុតសម្រាប់កម្ពុជា

ជីវិតកម្សាន្ត

កាលបរិច្ឆេទផ្សាយ:
២៤ វិច្ឆិកា ២០២៣ | ០៩:៥៥

អ្នកយកព័ត៌មាន:
ហុង រស្មី

ប្រធានបទផ្សេងៗ







ឈុត១នៃការសម្តែងរបស់ក្រុមហ្វារពន្លឺសិល្បៈ ។ រូបថត ហ្វារពន្លឺសិល្បៈ

**បាត់ដំបង** : ហ្វារពន្លឺសិល្បៈ ទទួលបានជយលាភីពីកម្មវិធី Shorty Impact Awards ប្រចាំឆ្នាំលើកទី៨ ក្នុងប្រភេទ «Contest & Challenges» ដោយធ្វើការប្រកួតប្រជែងក្នុងការបង្កើតកំណត់ត្រាពិភពលោកហ្គីនណេសតាមរយៈការសម្តែងសៀករយៈពេលវែងបំផុត ២៤ ម៉ោង ៣០នាទី និង ១០វិនាទី បំណងកៀរគរមូលនិធិដ៏សំខាន់សម្រាប់ការរស់រានក្នុងអំឡុងពេលជួបវិបត្តិជំងឺឆ្លងរាតត្បាតសកល។

ពានរង្វាន់អន្តរជាតិរបស់កម្មវិធី Shorty Impact Awards ផ្តល់កិត្តិយសដល់ប្រព័ន្ធផ្សព្វផ្សាយបែបឌីជីថល និងប្រព័ន្ធផ្សព្វផ្សាយសង្គមដ៏ល្អបំផុត ទៅកាន់អង្គការឬស្ថាប័នណាមួយដែលធ្វើការដើម្បីធ្វើឱ្យពិភពលោកក្លាយទៅជាកន្លែងដ៏ល្អប្រសើរជាងមុន។

លោក អូស្មាន់ ខារ៉ាចា នាយកប្រតិបត្តិនៃសមាគមហ្វារពន្លឺសិល្បៈ បានឱ្យដឹងថា៖ «យើងពិតជាមានក្តីរំភើបជាខ្លាំងដែល ត្រូវបានទទួលស្គាល់ដោយពានរង្វាន់អន្តរជាតិ Shorty Impact Awards ដែលបញ្ជាក់ និងជាកម្លាំងជំរុញឱ្យឃើញថាកំណត់ត្រាពិភពលោកសៀករយៈពេល២៤ម៉ោងរបស់សមាគមហ្វារពន្លឺសិល្បៈបានជួយដល់ការដាក់បញ្ចូលខេត្តបាត់ដំបង និងប្រទេសកម្ពុជានៅលើទិសដៅសិល្បៈ និងវប្បធម៌»។

ហ្វារពន្លឺសិល្បៈគឺជាស្ថាប័នតែ១គត់នៅកម្ពុជាដែលត្រូវបានទទួលស្គាល់ចំពោះសមិទ្ធផលក្នុងការកៀរគរមូលនិធិ និងការលើកស្ទួយសិល្បៈ វប្បធម៌ ក៏ដូចជាភាពច្នៃប្រឌិតដោយបានយកឈ្នះម៉ាកយីហោធំៗដ៏ល្បីផ្សេងទៀតដូចជា៖ M&M's និង RuPaul's Drag Race ដែលបានចូលរួមប្រកួតក្នុងប្រភេទវិញ្ញាសាដូចគ្នានោះផងដែរ។

អង្គការ និងស្ថាប័នជាច្រើនប្រទេសមកពីជុំវិញពិភពលោកបានចូលរួមប្រកួតប្រជែង Shorty Impact Awards រួមមាន សហរដ្ឋអាមេរិក កាណាដា ឥណ្ឌា អ៊ុយក្រែន អង់គ្លេស ប៉ាឡេស្ទីន និងហ្វីលីពីនជាដើម។ ម្ចាស់ជយលាភី មានដូចជា Barbie, UNICEF, Elton John, Facebook, Amazon, Al-Jazeera, Mercedes និង Dwayne "The Rock" Johnson។

យោងតាមនាយកប្រតិបត្តិនៃសមាគមហ្វារពន្លឺសិល្បៈ បានឱ្យដឹងថា អ្នកឈ្នះពានរង្វាន់ជយលាភី Shorty Impact Awards ប្រចាំឆ្នាំលើកទី៨ ត្រូវបានប្រកាសកាលពីថ្ងៃទី១៣ ខែវិច្ឆិកា នៅក្នុងពិធីដោយផ្ទាល់នៅក្នុងសាល The Belasco ទីក្រុង Los Angeles។ កម្មវិធីនេះមានអ្នកចូលរួមជាង ២០០ នាក់មកពីជុំវិញពិភពលោក និងសមាជិក Real Time Academy ល្បីៗមួយចំនួន។

លោកបានឱ្យដឹងថា អ្នកឈ្នះពានរង្វាន់ Shorty Impact Award ត្រូវបានជ្រើសរើសដោយ Real Time Academy (RTA) ជាអ្នកជំនាញ និងអ្នកដឹកនាំលេចធ្លោក្នុងប្រព័ន្ធផ្សព្វផ្សាយឌីជីថល និងបណ្តាញសង្គម ដែលត្រូវបានជ្រើសរើសដោយផ្ទាល់ ផ្អែកលើចំណេះដឹងដ៏ជ្រៅជ្រះក្នុងឧស្សាហកម្ម កេរ្តិ៍ឈ្មោះវិជ្ជាជីវៈ និងសមិទ្ធផលឆ្នើម រួមទាំងស្នាដៃ shorty ពីមុនៗផងដែរ។

រត់ ឬជិះកង់តាមដងស្ទឹងសង្កែ ចម្ងាយ៣០គីឡូម៉ែត្រ ដើម្បីអបអរសាទរខួប៣០ឆ្នាំ

ដើម្បីអបអរខួបឆ្នាំទី ៣០ នៃការបង្កើតអង្គការសមាគមហ្វារពន្លឺសិល្បៈ ព្រឹត្តិការណ៍រត់ ឬជិះកង់ ៣០ គីឡូម៉ែត្រតាមដងស្ទឹងសង្កែ ត្រូវបានរៀបចំឡើងក្នុងគោលបំណងរំឭក









## ព័ត៌មានថ្មីៗ


កម្ពុជា-ថៃ បង្ហាញឆន្ទៈក្នុងការបន្តកិច្ចសហការលើការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សទ្វេភាគី

រដ្ឋមន្ត្រីក្រសួងសុខាភិបាល ស្នើមន្ត្រីសុខាភិបាលទាំងអស់ យកចិត្តទុកដាក់ផ្តល់សេវាសុខាភិបាលឱ្យបានល្អថែមទៀតនៅថ្ងៃអុំទូកចុងក្រោយ

រដ្ឋមន្ត្រីរ៉ែ៖ ក្រុមហ៊ុនអូស្ត្រាលី ដែលកំពុងជីករករ៉ែមាសនៅមណ្ឌលគិរី ចង់ពង្រីកវិនិយោគទៅកាន់ខេត្តត្បូងឃ្មុំ

មន្ត្រី៖ មិនមានក្តីព្រួយបារម្ភពីបញ្ហាគ្រឿងញៀន នៅក្នុងព្រះរាជពិធីបុណ្យអុំទូកឡើយ ប៉ុន្តែសមត្ថកិច្ចនៅតែយកចិត្តទុកដាក់ខ្ពស់

សភាពាណិជ្ជកម្មកម្ពុជា គ្រោងនឹងរៀបចំវេទិកាធុរកិច្ចកម្ពុជា-អូស្ត្រាលី នាខែមីនា ឆ្នាំ២០២៤ ខាងមុខនេះ នៅអូស្ត្រាលី

ក្រុមអង្គការសង្គមស៊ីវិល ២០ស្ថាប័ន ស្នើឱ្យរាជរដ្ឋាភិបាលអាណត្តិថ្មីឆ្លើយតបតម្រូវការចាំបាច់របស់ស្ត្រី

រដ្ឋមន្ត្រីសុខាភិបាលវាយតម្លៃខ្ពស់ចំពោះគ្រូពេទ្យប្រចាំការ ខណៈរយៈពេល ២ថ្ងៃផ្តល់សេវាសុខាភិបាលជូនពលរដ្ឋជាង ៣ ពាន់នាក់

អគ្គស្នងការនគរបាលជាតិ កោតសរសើរកងកម្លាំងដែលបំពេញភារកិច្ចបានល្អ និងជំរុញការយកចិត្តទុកដាក់បន្ថែមទៀត

ចំណាប់ខ្មាំងកាន់តែច្រើនរំពឹងថា នឹងត្រូវដោះលែង ខណៈមានការអូសបន្លាយពេលនៃបទឈប់បាញ់ ហាម៉ាស់-អ៊ីស្រាអែល

មន្ត្រីបរិស្ថាន៖ ពលរដ្ឋដើរកម្សាន្តបុណ្យអុំទូកឆ្នាំនេះ